**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ៦២៩ MOC / SM 2008

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់
## នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៩អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## <u>សម្រេច</u>

**<u>ប្រការ១</u> : នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ** ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មានតួនាទី និងភារកិច្ចដូចតទៅ ៖-

- តាមដាន និងសន្និដ្ឋានវាយតម្លៃនូវការងារត្រួតពិនិត្យ និងអង្កេតថ្នាក់ជាតិផ្នែកគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវាក្នុងក្របខ័ណ្ឌ នៃសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- រៀបចំតាក់តែងកែសម្រួលវិធីសាស្ត្រ នៃការងារអង្កេតពាក់ព័ន្ធនឹង គុណភាព សុវត្ថិភាព ផលិតផល
- រៀបចំតាក់តែងសៀវភៅណែនាំការត្រួតពិនិត្យ
- រៀបចំកសាងកម្រងព័ត៌មាន នៃគ្រោះសម្រាប់ការអនុវត្តកិច្ចត្រួតពិនិត្យការនាំចេញ នាំចូល ដោយផ្អែកលើគោលការណ៍ នៃការគ្រប់គ្រងហានិភ័យ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៥៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

- រ៉ាប់រងបន្ថែមជាមួយសាខា នូវកិច្ចការត្រួតពិនិត្យតាមខេត្ត-ក្រុង សម្រាប់អនុវត្តកិច្ចការអង្កេតពិសេសទាំងឡាយ
- ដឹកនាំក្រុមអង្កេតពិសេសសម្រាប់អនុវត្តកិច្ចការអង្កេតពិសេសនានា ដែលមានលក្ខណៈពិសេសស្មុគស្មាញ
- កសាងគោលនយោបាយកិច្ចការអ្នកប្រើប្រាស់ពាក់ព័ន្ធនឹងទំនិញ សេវាកម្ម ជាអាទិ៍ ការដាក់ស្លាកសញ្ញា ការឃោសនាពាណិជ្ជកម្មភូតកុហក ការបន្លំពាក់ព័ន្ធនឹងផលិតផល និងសេវាកម្ម
- រៀបចំកម្មវិធីតាមដាន និងសន្និដ្ឋានវាយតម្លៃការងារអង្កេតថ្នាក់ជាតិពាក់ព័ន្ធនឹង កិច្ចការអ្នកប្រើប្រាស់ ក្រៅពីបញ្ហាគុណភាព សុវត្ថភាពផលិតផល និងសេវា
- ទទួលពិនិត្យដោះស្រាយនូវពាក្យបណ្តឹងតវ៉ារបស់សាធារណជន ឬស្ថាប័នសាធារណៈ
- ជំរុញបង្កើត ឬគាំទ្រចលនាអ្នកប្រើប្រាស់
- រៀបចំអនុវត្តកម្មវិធីផ្តល់ព័ត៌មានអប់រំ និងផ្តល់ការយល់ដឹងដល់អ្នកប្រើប្រាស់
- ដឹកនាំ សម្របសម្រួល និងអនុវត្តកិច្ចការត្រួតពិនិត្យពាណិជ្ជកម្មពាក់ព័ន្ធដល់ការនាំចូល និងនាំចេញទំនិញ ឬការប្រគល់ទទួលក្នុងប្រទេសតាមសំណើរបស់ការីសេដ្ឋកិច្ច
- រៀបចំតាក់តែងកែសម្រួលវិធីសាស្ត្រ នៃការងារអង្កេតពាក់ព័ន្ធនឹង គុណភាព សុវត្ថិភាព ផលិតផល
- ដឹកនាំក្រុមអង្កេតពិសេសសម្រាប់អនុវត្តកិច្ចការអង្កេតពិសេសនានា ដែលមានលក្ខណៈពិសេសស្មុគស្មាញ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

<u>**ប្រការ២**</u> : នាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់ និងបង្ក្រាបការក្លែងបន្លំ មាន ការិយាល័យចំណុះចំនួន ៤ ៖-

១-ការិយាល័យអង្កេត

២-ការិយាល័យបង្ក្រាបការក្លែងបន្លំ និងឃោសនាភូតកុហក

៣-ការិយាល័យដោះស្រាយបណ្តឹងរបស់អ្នកប្រើ និងផ្សព្វផ្សាយ

៤-ការិយាល័យត្រួតពិនិត្យពាណិជ្ជកម្ម

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន តាមការចាំបាច់ ។

<u>**ប្រការ៣**</u>**:** **ការិយាល័យអង្កេត** ទទួលបន្ទុក:

- តាមដាន និងសន្និដ្ឋានវាយតម្លៃនូវការងារត្រួតពិនិត្យ និងអង្កេតថ្នាក់ជាតិផ្នែកគុណភាព សុវត្ថិភាព ផលិតផលទំនិញ និងសេវា ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- រៀបចំតាក់តែងកែសម្រួលវិធីសាស្ត្រ នៃការងារអង្កេតពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផល និងសេវា
- រៀបចំតាក់តែងសៀវភៅណែនាំការត្រួតពិនិត្យ
- រៀបចំកសាងកម្រងព័ត៌មាន នៃគ្រោះសម្រាប់ការអនុវត្តកិច្ចត្រួតពិនិត្យការនាំចេញ នាំចូល ដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងហានិភ័យ
- រ៉ាប់រងបន្ថែមជាមួយសាខានូវកិច្ចការត្រួតពិនិត្យតាមខេត្ត ក្រុង សម្រាប់អនុវត្តកិច្ចការអង្កេតពិសេសទាំងឡាយ
- រួមដឹកនាំក្រុមអង្កេតពិសេសសម្រាប់អនុវត្តកិច្ចការអង្កេតពិសេសនានា ដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផល និងសេវា
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

**ប្រការ៤:** **ការិយាល័យបង្ក្រាបការក្លែងបន្លំ និងឃោសនាភូតកុហក** ទទួលបន្ទុក :

- កសាងគោលនយោបាយកិច្ចការអ្នកប្រើប្រាស់ពាក់ព័ន្ធនឹងទំនិញ សេវាកម្ម ជាអាទិ៍ការដាក់ស្លាកសញ្ញា ការឃោសនាពាណិជ្ជកម្មភូតកុហក ការបន្លំពាក់ព័ន្ធនឹងផលិតផល និងសេវាកម្ម
- រៀបចំកម្មវិធីតាមដាន និងសន្និដ្ឋានវាយតម្លៃការងារអង្កេតថ្នាក់ជាតិពាក់ព័ន្ធនឹងកិច្ចការអ្នកប្រើប្រាស់ ក្រៅពីបញ្ហាគុណភាព សុវត្ថិភាពផលិតផល និងសេវា
- រួមដឹកនាំក្រុមអង្កេតពិសេសសម្រាប់អនុវត្តកិច្ចការអង្កេតពិសេសនានា ដែលមានលក្ខណៈបច្ចេកទេសស្មុគ្រស្មាញ ក្រៅអំពីបញ្ហាគុណភាព សុវត្ថិភាពផលិតផល និងសេវា
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៥:** **ការិយាល័យដោះស្រាយបណ្តឹងរបស់អ្នកប្រើ និងផ្សព្វផ្សាយ** ទទួលបន្ទុកៈ

- ទទួលពិនិត្យដោះស្រាយនូវពាក្យបណ្តឹងតវ៉ារបស់សាធារណជន ឬស្ថាប័នសាធារណៈ
- ជំរុញបង្កើត ឬគាំទ្រចលនាអ្នកប្រើប្រាស់
- រៀបចំអនុវត្តកម្មវិធីផ្តល់ព័តិមានអប់រំ និងផ្តល់ការយល់ដឹងដល់អ្នកប្រើប្រាស់
- សម្របសម្រួលកិច្ចការការពារអ្នកប្រើក្នុងតំបន់ និងអន្តរជាតិ
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៦:** **ការិយាល័យត្រួតពិនិត្យពាណិជ្ជកម្ម** ទទួលបន្ទុកៈ

- ជំរុញកិច្ចសហប្រតិបត្តការជាមួយបណ្តាក្រុមហ៊ុនត្រួតពិនិត្យក្រៅប្រទេស ដើម្បីពង្រឹង និងពង្រីកទីផ្សារត្រួតពិនិត្យ
- ដឹកនាំ សម្របសម្រួល និងអនុវត្តកិច្ចការត្រួតពិនិត្យពាណិជ្ជកម្មពាក់ព័ន្ធដល់ការនាំចូល និងនាំចេញទំនិញ ឬការប្រគល់ទទួលក្នុងប្រទេសតាមសំណើរបស់ការីសេដ្ឋកិច្ច
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៧:** នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

-ដូចប្រការ៧

-ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៨ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីមែល : moccabdir@yahoo.com